**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន និងក្រុមហ៊ុននាំចូល និងចែកចាយទំនិញទាំងអស់ឱ្យបានជ្រាបថា អនុលោមតាមច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ និងប្រកាសស្តីពីនីតិវិធីសម្រាប់ការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ រាល់ការប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ត្រូវបញ្ជាក់ប្រភេទនៃទំនិញថ្មីឱ្យបានច្បាស់លាស់ ជាពិសេសចំពោះរថយន្ត ត្រីចក្រយានយន្ត និងទោចក្រយានយន្ត **ត្រូវបញ្ជាក់ម៉ូដែលឱ្យបានច្បាស់លាស់** មុននឹងយកមកស្នើសុំការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ នៅក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងក្រុមហ៊ុនទាំងអស់ ជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១៣រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

ឡូតិ៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្សី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469